# ការមើលថែជំនួសបណ្ដោះអាសន្ន

## អ្វីទៅជា ការមើលថែជំនួសបណ្ដោះអាសន្ន (Respite Care)

ប្រសិនបើអ្នករស់នៅតែម្នាក់ឯង ហើយមានអារម្មណ៍ថាពិបាកក្នុងការមើលថែខ្លួនឯង ហើយត្រូវការសម្រាក អ្នកអាចទទួលយកសេវាថែទាំសុខភាពក្នុងរយៈពេលខ្លី ពីអ្នកផ្ដល់សេវាថែទាំសុខភាព។ ប្រភេទនៃការសម្រាកដើម្បីទទួលយកសេវានេះ គេឱ្យឈ្មោះថា (Respite Care) ឬប្រសិនបើអ្នកថែទាំអ្នកត្រូវការពេលឈប់សម្រាកដើម្បីការងារផ្ទាល់ខ្លួន ឬដោយសារសុខភាពរបស់គាត់ ក្នុងលក្ខណៈបែបនេះ កិច្ចបំរើនេះក៏អាចត្រូវផ្ដល់ជូនបានផងដែរ មានន័យថា មានមនុស្សម្នាក់ទៀតនឹងទៅមើលអ្នកជំនួសអ្នកថែទាំអ្នកក្នុងរយៈពេលខ្លី បើទោះជាអ្នកនៅផ្ទះ ឬនៅមណ្ឌលសកម្មភាពពេលថ្ងៃ (Day Care Centre) ឬនៅក្នុងមណ្ឌលថែទាំមនុស្សចាស់ (Aged Care Home)។

## ការមើលថែជំនួសបណ្ដោះអាសន្ន (Respite Care) មានគោលបំណងពីរ

-ជួយដល់អ្នកមើលថែទាំងឡាយ ដើម្បីផ្ដល់ឱកាសឱ្យគេបានឈប់សម្រាករយៈពេលខ្លីពីការងារប្រចាំថ្ងៃរបស់គេ
-ផ្ដល់នូវការគាំទ្រ ដើម្បីឱ្យជនចាស់ជរាអាចបន្តការរស់នៅក្នុងផ្ទះរបស់គាត់ដោយស្រួល។

## ប្រភេទនៃ ការមើលថែជំនួសបណ្ដោះអាសន្ន (Type of Respite Care)

### -មណ្ឌលសកម្មភាពពេលថ្ងៃ (Day Care Centre)

មានរយៈពេល កន្លះថ្ងៃ មួយថ្ងៃ ឬបន្ថែមថ្ងៃ "ការថែទាំរយៈពេលវែង" ការថែទាំដើម្បីឱ្យមានពេលឈប់សម្រាកត្រូវបានផ្ដល់ នៅឯមណ្ឌលសកម្មភាពពេលថ្ងៃ ក្នុងទូទាំងប្រទេស។

### -ការថែទាំតាមផ្ទះ (In-home care)

អ្នកថែទាំអាចទៅដល់ផ្ទះរបស់លោកអ្នកដើម្បីផ្ដល់នូវការបម្រើសមស្រប ឬក៏អាចនាំមនុស្សដែលអ្នកមើលថែទៅខាងក្រៅដើរលំហែរ នៅពេលដែលអ្នកចង់សម្រាកនៅផ្ទះឱ្យបានស្រួល និង ស្ងប់ស្ងាត់មួយពេល។

**-ការថែទាំពេលយប់រៀបចំដោយសហគមន៍** (Overnight respite in a community setting)

ការថែទាំប្រភេទនេះអាចធ្វើ នៅកន្លែងផ្តល់សេវាកម្មថែទាំ ឬនៅផ្ទះដែលរៀបចំដោយគ្រួសារ ឬនៅសណ្ឋាគារ ឬកន្លែងផ្សេងៗទៀតដែលបានរៀបចំរួចហើយ ។

**- ការមើលថែជំនួសបណ្តោះអាសន្ន សម្រាប់អ្នកថែទាំដែលជាប់រវល់ធ្វើការ** (Respite for working carer)

ប្រភេទនៃការថែទាំនេះអាចជួយដល់អ្នកថែទាំដែលរវល់នឹងការងារ ហើយអ្នកមានវ័យទ្រុឌទ្រោម ឬអ្នកមើលថែដែលកំពុងទទួលការបណ្តុះបណ្តាល ដើម្បីឱ្យគេអាចទៅធ្វើការងារវិញបាន ។

**- ការមើលថែជំនួសបណ្តោះអាសន្ន នៅមណ្ឌលជនចាស់ជរា** (Aged care home)

កិច្ចបំរើរយៈពេលខ្លីក៏អាចមានផងដែរនៅមណ្ឌលជនចាស់ជរាសម្រាប់អ្នកទាំងឡាយណាដែលត្រូវការ ការថែទាំជាបណ្តោះអាសន្ន។ ការមើលថែជំនួសបណ្តោះអាសន្ន (Respite Care) នៅមណ្ឌលជនចាស់ជរាអាចនឹងផ្តល់ទៅតាមផែនការ ឬនៅក្នុងករណីបន្ទាន់ដើម្បីជួយកាត់បន្ថយភាពតានតឹងរបស់អ្នកមើលថែ ពេលឈឺ ពេលឈប់សម្រាក ឬពេលដែលអ្នកមើលថែជាប់រវល់នឹងបញ្ហាផ្សេង ។

**ភាពស្របច្បាប់ដែលអាចទទួលយកសេវា ការមើលថែជំនួសបណ្តោះអាសន្ន (Respite Care)**

ដើម្បីទទួលយកសេវានេះអ្នកត្រូវមានភាពសមស្របតាមលក្ខណៈសម្បត្តិ ដោយមើលទៅលើអទិភាព និង សេចក្តីត្រូវការ ។ សម្រាប់ការថែទាំដើម្បីឱ្យមានពេលឈប់សម្រាក (Respite Care) នៅសហគមន៍ នៅផ្ទះ ឬនៅមណ្ឌលសកម្មពេលថ្ងៃ អ្នកអាចទំនាក់ទំនង តាមទូរសព្ទ **១៨០០ ០៥២ ២២២** ក្នុងពេលម៉ោងធ្វើការ ឬពេលអ្នកត្រូវការបន្ទាន់ ទំនាក់ទំនងតាមទូរសព្ទលេខ **១៨០០ ០៥៩ ០៥៩** ។ នៅទីកន្លែងនេះនឹងអាចវាយតម្លៃថាតើអ្នក ឬមនុស្សដែលអ្នកថែទាំមានលក្ខណៈសមស្របទទួលសេវាដែរឬទេ? ។

**តើមនុស្សម្នាក់អាចទទួលសេវា ការមើលថែជំនួសបណ្តោះអាសន្ន នៅសហគមន៍ (Community Respite)រយៈពេលប៉ុន្មាន?**

ការស្នើសុំនីមួយៗត្រូវវាយតម្លៃទៅលើបុគ្គលផ្ទាល់ អាស្រ័យលើសេចក្តីត្រូវការរបស់អ្នក និង សេចក្តីត្រូវការរបស់សាច់ញាតិផងដែរ ហើយ ចំពោះការផ្តល់សេវា ការមើលថែជំនួសបណ្តោះអាសន្ន គឺត្រូវបានផ្តល់ឱ្យដោយយុត្តិធមិតាមដែលអាចធ្វើទៅបាន។

អ្នកមើលថែមួយចំនួនមានការសប្បាយចិត្តចំពោះរយៈពេល ៣ ទៅ ៤ម៉ោង ធ្វើការនៅក្នុងកន្លែងថែទាំជនចាស់ជារា ឬ មួយថ្ងៃ ឬ ពីរថ្ងៃនៅមណ្ឌលសកម្មភាពពេលថ្ងៃ (Day Care Centre)។ ហើយចំពោះអ្នកខ្លះទៀតធ្វើការជាអ្នកថែទាំ ដែលមើលថែសមាជិកគ្រួសារច្រើនជាងមួយ អាចត្រូវការការថែទាំរយៈពេលវែងបន្តិចសម្រាប់អ្នកដែលគេមើលថែ។

## ការរៀបចំ ការមើលថែជំនួសបណ្តោះអាសន្ន នៅកន្លែងជនចាស់ជរា (Aged care home)

ចំពោះអ្នកណាម្នាក់ដែលមានបំណងរៀបចំ ការមើលថែជំនួសបណ្តោះអាសន្ន នៅតាមមណ្ឌលថែទាំមនុស្សចាស់បើទោះជា សម្រាប់ខ្លួនគេ ឬសម្រាប់មនុស្សដែលគេថែទាំ គួរធ្វើការទំនាក់ទំនងជាមួយ ក្រុមវាយតម្លៃ Aged Care Assessment Team (ACAT)។ (ACAT) តែងតែមានការិយាល័យនៅតាមមន្ទីពេទ្យ ឬនៅតាមមណ្ឌលក្នុងសហគមន៍ (Community Centre)ហើយអាចមានវេជ្ជបណ្ឌិត គិលានុបដ្ឋាយិការ បុគ្គលិករដ្ឋ សម្រាប់ពិភាក្សានិងទំនាក់ទំនង។

ការណាត់ជួបធ្វើឡើងតែម្តង និងមានបុគ្គលិក (ACAT) ទៅជួបលោកអ្នកនៅផ្ទះ ឬមន្ទីពេទ្យដើម្បីធ្វើការវាយតម្លៃមនុស្សដែលអ្នកថែទាំ។ ក្រុមនិងពិភាក្សាជាមួយអ្នក និង អ្នកដែលអ្នកមើលថែ ថាតើសេចក្តីត្រូវការអ្វីខ្លះដែលសេវាកម្មគួផ្តល់ និង អ្វីខ្លះដែលអាចមានស្រាប់នៅតំបន់ដែលអ្នករស់នៅ។

## តើមនុស្សម្នាក់អាចទទួលយកសេវាកម្ម ការមើលថែជំនួសបណ្តោះអាសន្ន នៅតាមលំនៅដ្ឋាន (Residential Respite) រយៈពេលប៉ុន្មាន?

នៅក្នុងករណីជាច្រើន មនុស្សម្នាក់អាចទទួលសេវារហូតដល់ទៅ៦៣ថ្ងៃក្នុងឆ្នាំសារពើពន្ធ។ ទោះបីជាយ៉ាងណាក៏ដោយប្រសិនបើក្រុមវាយតម្លៃមើលឃើញថា វាជាការចាំបាច់អាចបន្ថែមរហូតដល់២១ថ្ងៃក្នុងមួយលើក។

## តម្លៃសម្រាប់សេវា នៃការថែទាំដើម្បីឱ្យមានពេលឈប់សម្រាក

ពុំមានការគិតតម្លៃចំពោះការជួយពី Commonwealth Respite and Carelink Centres ទេ ប៉ុន្តែ នៅពេលដែលអ្នកទទួលយកសេវាតាមរយៈការបញ្ជូនពី Commonwealth Respite and Carelink Centres អ្នកអាចនឹងត្រូវចំណាយសម្រាប់សេវានោះ។

សេវាកម្ម ការមើលថែជំនួសបណ្តោះអាសន្ន គិតតម្លៃទៅតាមប្រភេទនៃសេវាដែល លោកអ្នកទទួល។

## តម្លៃសេវាកម្ម ការមើលថែជំនួសបណ្តោះអាសន្ន នៅកន្លែងជនចាស់ជរា

ចំពោះអ្នកដែលនៅក្នុងមណ្ឌល ហើយទទួលសេវាការថែទាំ ដែលផ្តល់ថវិកាគាំទ្រដោយរដ្ឋាភិបាល អាចស្នើឱ្យមានការចំណាយ ៣២,៩៥ដុល្លា ក្នុងមួយថ្ងៃ។ ក្នុងករណីនេះ តម្លៃកក់ អាចនឹងត្រូវបានគិតថ្លៃដើម្បីធានាបាននូវកន្លែងស្នាក់នៅ។ នេះគឺជាតំណាក់កាលចំណាយដំបូង ហើយពុំមានការចំណាយបន្ថែមទៀតទេ។ ជាងនេះទៅទៀត វាមិនអាចច្រើនជាងតម្លៃពេញមួយសប្តាហ៍ទេ ឬ ២៥ភាគរយ នៃតម្លៃស្នាក់នៅ ដែលមានចំនួនទាបបំផុត។

## តម្លៃសេវាកម្ម ការមើលថែជំនួសបណ្តោះអាសន្ន នៅតាមផ្ទះ និង មណ្ឌលសកម្មភាពពេលថ្ងៃ

ចំពោះអ្នកដែលទទួលសេវានេះ នៅតាមផ្ទះ និង នៅមណ្ឌលត្រូវចំណាយអាស្រ័យទៅតាមប្រភេទនៃកិច្ចបំរើដែលអ្នកទទួល។ ចំនួនចំណាយអាចនឹងមានខុសគ្នា ទៅតាមម៉ោងដែលគេផ្តល់សេវានៅផ្ទះ និង ទៅតាមរយៈពេលនីមួយៗនៅក្នុងមណ្ឌលសំរាប់ពេលព្រឹក ឬ ពេលថ្ងៃ។

## ការផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់អ្នកមើលថែជំនួសបណ្តោះអាសន្ន

ការជំនួយហិរញ្ញវត្ថុ គឺអាចធ្វើទៅបានសម្រាប់អ្នកមើលថែទាំងឡាយណាដែលមាលក្ខណៈសម្បត្តិសមស្រប ដោយ Carer Payment or Carer Allowance។ ប្រសិនបើអ្នកជាអ្នកមើលថែ ហើយទទួលថវិកាពីកន្លែងទាំងពីរនេះ អ្នកអាចបន្តទទួលរហូតដល់៦៣ថ្ងៃ នៅក្នុងករណី អ្នកដែលលោកអ្នកមើលថែកំពុងតែទទួលសេវាការមើលថែជំនួសបណ្តោះអាសន្ន ឬ កំពុងស្នាក់នៅបណ្តោះអាសន្ននៅក្នុងមន្ទីពេទ្យ។

## ការទំនាក់ទំនង ដើម្បីទទួលសេវាកម្ម ការមើលថែជំនួសបណ្ដោះអាសន្ន។

Commonwealth Respite and Carelink Centres ជាអ្នកឯកទេសក្នុងការជួយអ្នកមើលថែទាំងឡាយក្នុងការប្រើសេវាកម្ម ការមើលថែជំនួសបណ្ដោះអាសន្ន (Respite Care) ក្នុងតំបន់ដែលគេរស់នៅ។ ពត៌មានអំពីប្រភេទផ្សេងៗនៃ ការមើលថែជំនួសបណ្ដោះអាសន្ន (Respite Care) អាចដឹងបានដោយទំនាក់ទំនងទៅ Commonwealth Respite and Carelink Centres តាមទូរសព្ទលេខ ១៨00 0៥២ ២២២ រាល់ម៉ោងធ្វើការ និងក្នុងករណីត្រូវការសេវាកម្មបន្ទាន់ សូមទំនាក់ទំនងលេខ ១៨00 0៥៩ 0៥៩។

មានទីកន្លែងធ្វើការផ្សេងៗទៀតដែលអាចទំនាក់ទងពតិមាន អំពីការថែទាំដើម្បីឱ្យមានពេលឈប់សម្រាកបានដូចជា :

-ពតិមានអំពីការថែទាំជនចាស់ជរា ១៨00 ៥00 ៨៥៣

-ក្នុងទំព័រនិយាយពីជនចាស់ជរា នៅក្នុងសៀវភៅទូរសព្ទភាគច្រើន

-សមាគមអ្នកថែទាំនៅតាមរដ្ឋ និង ដែនដីនីមួយៗ ១៨00 ២៤២ ៦៣៦

-នាយកដ្ឋានរដ្ឋដែលពាក់ព័ន្ធនឹងការថែទាំជនចាស់ជរា

-ប្រសិនបើលោកអ្នកពុំចេះភាសាអង់គ្លេស សូមទូរសព្ទលេខ ១៣១ ៤៥0 ដើម្បីធ្វើការទំនាក់ទំនង។